n° 9. année 43. R. 25-10-43 K-275

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ពោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ឃុនវិពុទ្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ លោកអាចារ្យ កេវ-ស៊ុម អ្នកត្រួតត្រា សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

**ផ្នែកអក្សរសាស្ត្រ** — ទំព័រ

លោកគ្រូព្រះអាចារ្យ ពាង-សុខ . — ជាតកសុភាសិត . . . . . . . . . . . . ៤៩៩

អ្នកអាចារ្យ ជឹម-អាន . . . . . — រឿងព្រះបាទអសោកមហារាជ (តមក) . . . . ៥០៤

រឿងព្រេងខ្មែរៈ "និទានមាន់ខ្លាក់" (តមកនឹងចប់) ៥២៤

**ផ្នែកសាសនា**

ព្រះបាឡាត់ ធម្មបញ្ញាញាណ ស៊ុន-ហ៊ីន . . . . . . . — ធម្មាធិប្បាយ . . . . . . . . . . . . . . . ៥៣៣

លោកគ្រូចៅអធិការជិន-នាក់ . — ប្រវត្តិលោកគ្រូចៅអធិការពៅ-កើត . . . . . ៥៣៩

ដំណឹងពីក្រសួងធម្មការ . . . . — អំពីតាំងចៅអធិការនិងមន្ត្រីសង្ឃ . . . . . . . ៥៤៤

— — . . . . — អំពីអនុញ្ញាតឲ្យធ្វើបុណ្យបញ្ចុះសីមានៅវត្តនានា ៥៤៩

ឆ្នាំគំរប់ទី ១៥ — លេខ ៩ ខែសេបតម្ប៍ ១៩៤៣ — ដំឡៃជាវៈ ១ ឆ្នាំ ១០ រៀល ។

75

ធម្មាធិប្បាយ

"ធម្មកាមតា"

សេចក្តីប្រាថ្នាគុណធម៌ដែលប្រពៃ ។

ព្រះបាឡាត់ធម្មបញ្ញាញាណ ស៊ិន-ហ៊ាន

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។

សេចក្តីប្រាថ្នាបានដល់អាការៈដែលចិត្តមានបំណង ត្រូវអារម្មណ៍ក្នុងវត្ថុនោះៗ គឺឃើញតែរបស់ល្អគាប់ចិត្ត ពេញចិត្ត ទើបប្រាថ្នានឹងធ្វើវត្ថុនោះៗ ។ ពាក្យថាកាមៈនោះ នៅជាពាក្យកណ្តាល បានទាំងខាងល្អទាំងខាងអាក្រក់ តាមអំណាចធម៌ដែលបង្អោនទៅ តាមសព្ទគឺពាក្យថា ធម្មកាមតា បានជាសេចក្តីប្រាថ្នាខាងផ្លូវល្អ សេចក្តីប្រាថ្នាខាងផ្លូវលោក ប៉ែកខាងអាក្រក់នាំឲ្យដល់នូវសេចក្តីទុក្ខ បានជាកាមៈចំណែកអាក្រក់ គប្បីជ្រាបដោយន័យពុទ្ធភាសិតថា:

កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ

កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកនិងភ័យ តែងកើតមកតែអំពីកាម បើប្រាសចាកកាមហើយ សេចក្តីសោកក្តី ភ័យក្តី នឹងមានមកអំពីណា ។

អធិប្បាយថា: សេចក្ដីគាប់ចិត្ត សេចក្ដីប្រាថ្នាចំពោះសង្ខតធម៌ ដែលមានបច្ច័យប្រុងតែង ជាអវិញ្ញាណកទ្រព្យ គឺទ្រព្យដែលមិនមានវិញ្ញាណ មានមាសប្រាក់ជាដើមក្ដី ជាសវិញ្ញាណកទ្រព្យ គឺទ្រព្យដែលមានវិញ្ញាណគ្រប់គ្រង មានគោ ក្របី ដំរី សេះ ជាដើមក្ដី ឬជាវត្ថុកាម ដែលគួរប្រាថ្នាបានដល់រូប សំឡេង ក្លិន រស ផោដ្ឋព្វក្ដី ដែលជាសភាពកើតមានក្នុងខាងដើម ប្រែប្រួលទៅក្នុងកណ្ដាល រលត់ទៅក្នុងទីបំផុត កាលបើមានសេចក្ដីប្រាថ្នាប្រកាន់មាំថាជារបស់ថាវរៈ ព្រោះវិបត្តិដោយទិដ្ឋិហើយ លុះវត្ថុសភាពនោះៗ ព្រាត់ប្រាសវិនាសដោយបែកធ្លាយរលត់សូន្យទៅ អ្នកប្រាថ្នាដែលវិបត្តិដោយទិដ្ឋិក៏រមែងមានសេចក្ដីសោកបរិទេវទុក្ខទោមនស្សជាដើម ៗ សូម្បីភយន្តរាយក៏នៅស្ទាក់ចាំជុំវិញខ្លួន ដូចចោរឃ្លាំចាំប្រទូស្តកាយដណ្ដើមយករបស់ទ្រព្យគេ កាលមិនបានតាមប្រាថ្នា តែងប្រទូស្តកាយអ្នកម្ចាស់របស់ទ្រព្យខ្លះក៏មាន ៗ ចំណែកបុគ្គលអ្នកមានប្រាជ្ញា សូម្បីមានទ្រព្យសម្បត្តិ ក៏មិនស្វិតស្វាញប្រកាន់មាំប្រាថ្នាតែងនឹងលះបង់ចែកឲ្យជាប្រយោជន៍ខ្លួននឹងអ្នកដទៃ តាមគួរដល់ឋានៈ ព្រមទាំងស្គាល់ដឹងនូវគតិនៃធម្មតារបស់សង្ខតធម៌ លុះវត្ថុនោះប្រព្រឹត្តទៅតាមសភាព ក៏មិនមានសេចក្ដីសៅសោក ទាំងភយន្តរាយក៏មិនមានទោះបីខ្វខងក៏នឹងត្រវាកហានទៅ មិនបានមានសេចក្ដីព័ន្ធព័ទ្ធដែលជាគ្រឿងកំរើកចិត្ត សេចក្ដីប្រាថ្នាដូចអធិប្បាយមកនេះ ចាត់ជាកាម:

បែកខាងផ្លូវលោក ៗ ចំណែកសេចក្ដីប្រាជ្ញាខាងផ្លូវល្អ បានដល់សេចក្ដីប្រាជ្ញាក្នុងធម៌ដែលប្រពៃ ជាសាសនធម៌ សំដៅយកបាវចនៈ គឺធម៌និងវិន័យ ជាពាក្យប្រដៅរបស់ព្រះដ៏មានព្រះភាគ សេចក្ដីប្រតិបត្តិសម្រាប់ហ្វឹកហាត់អធ្យាស្រ័យឲ្យថ្លៃថ្នូរ ចាត់ជាធម៌ ៗ សេចក្ដីប្រតិបត្តិដ៏ជាប់ដោយរបៀប ដែលព្រះអង្គទ្រង់តាំងទុកជាពុទ្ធអាណា ជាសិក្ខាបទ ឬជាអភិសមាចារ ស្ទួយសេចក្ដីប្រព្រឹត្តិរបស់ពួកគណៈឲ្យស្មើភាគគ្នា ឬជាគ្រឿងបរិហារគណៈ ចាត់ជាវិន័យ ៗ ន័យមួយទៀត ពាក្យថាធម៌នេះបានដល់ សីល សមាធិ បញ្ញា ៗ សីល បានដល់វិន័យ សមាធិនិងបញ្ញា ចាត់ជាធម៌ដូចពោលហើយក្នុងបាវចនៈ ៗ ន័យមួយវិញទៀតបានដល់សទ្ធម្ម៣ប្រការគឺ បរិយត្តិសទ្ធម្ម បានដល់ពាក្យប្រដៅ, បដិបត្តិសទ្ធម្ម បានដល់សេចក្ដីប្រតិបត្តិ, បដិវេធសទ្ធម្ម បានដល់មគ្គផលនិព្វាន, ធម៌មានប្រភេទដូចបរិយាយមកនេះ ឈ្មោះថាធម៌ដែលប្រពៃជាស្វាក្ខាតធម៌ដែលព្រះអង្គត្រាស់ល្អហើយ កាលមានសេចក្ដីប្រាជ្ញាធ្នូ. ក៏បង្កើតឡើងជាសម្បជ្ជានដែលជាប់ទាក់ទិននឹងការៈទំកបិត្ត ធ្នូៈនេះលោកចាត់ជាឥទ្ធិបាទ គុណគ្រឿងសម្រេចបំណងជាអង្គពោធិបក្ខិយធម៌ គឺធម៌ជាផ្នែកនៃសេចក្ដីត្រាស់ដឹងប្រការមួយ ៗ កាមៈនិងធ្នូៈនេះកាចទង់ទាញចង់គៀកសេចក្ដីព្យាយាមទុកមិនឲ្យធូរថយ គប្បីឃើញតួយ៉ាងដូចសម្ដេចព្រះបរមសាស្ដា ព្រះអង្គទ្រង់អាស្រ័យកាមៈនិងធ្នូៈដែលជាផល

នៃព្រះមហាករុណា ទើបបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធបំពេញពុទ្ធ-កិច្ចប្រតិស្ឋានព្រះពុទ្ធសាសនាសម្រេចបានដល់សព្វថ្ងៃនេះ ។ បើតាមៈ នឹងឆន្ទៈមិនមាននៅក្នុងព្រះហឫទ័យព្រះអង្គទេ ក្នុងខណៈដែលទ្រង់សាង មហាភិនេស្រ្កមបំពេញទុក្ករកិរិយា មុខតែអត់ធន់បំពោះទុក្ខលំបាកមិនបាន គង់នឹងត្រឡប់វិលក្រោយដាក់ធុរៈពោលមិនប្រឹងប្រែងតទៅទៀត ញាក់នៅក្នុងអំណាចនៃមារជាមិនខាន ។ មួយទៀត កាលព្រះអង្គទ្រង់ពិ-ចារណាឃើញធម៌ដែលព្រះអង្គត្រាស់ដឹងនោះ ថាជាគុណជាតដ៏សុខុម ល្អិតក្រៃពេកកម្រមានពួកសត្វនិករណានឹងត្រេកអរដឹងតាមឃើញតាមបាន ព្រះហឫទ័យក៏បង្អោនទៅក្នុងផ្លូវខ្វល់ខ្វាយតិច ទើបមិនទ្រង់ព្រះតម្រិះនឹងសំដែងធម៌ តែសេចក្តីប្រាថ្នានឹងសេចក្តីពេញព្រះហឫទ័យជាកំឡាំងព្រះមហាករុណាចូលទៅឧបត្ថម្ភដាស់គ្នាហើយ ទើបទ្រង់មិនបានបោះបង់ធុរៈនោះពោល ទ្រង់ពិតពិលពិចារណាទៅក៏ទតព្រះនេត្រឃើញអ្នកមានបញ្ញាអាចដឹងតាមនៅមាន ។ បំណែកមនុស្សក្រៅពីនេះក៏ល្មមនឹងអប់រំសម្មាបដិបត្តិជាលំដាប់លំដោយគ្នាបានដែរ យ៉ាងតិចក៏អាចបានទទួលប្រយោជន៍ជាលោកិយ លើកទុកតែអកតញ្ញូបុគ្គលមួយពួកមិនបានសម្រេចគុណវិសេសឡើយ ព្រោះមិនបានតាំងចិត្តស្តាប់ធម៌ដោយគោ-រព ប្រៀបដូចផ្កាឧប្បលដុះលូតលាស់ឡើងផុតអំពីទឹកហើយ បម្រុងនឹង

រីកដល់វេលាព្រះអាទិត្យរះឡើង ដុះលូតលាស់នៅត្រើមស្ទឹងនឹងទឹកខ្លះ ដុះលូតលាស់នៅក្នុងទឹកមានទឹកសម្រាប់បំពេញមរគ្យាទុកខ្លះ ដុះលូតលាស់ត្រាន់តែជាចំណីនៃអណ្តើកនិងត្រីខ្លះ លុះទ្រង់ពិចារណាដូច្នេះហើយ ទើបទ្រង់អធិដ្ឋានតាំងព្រះហឫទ័យប្រកាសព្រះសាសនា ទ្រង់មិនបានឃើញដល់សេចក្តីនឿយហត់លំបាកព្រះកាយពល បានប្រកាសព្រះសាសនាឲ្យផ្សាយធំទូលាយ ដោយព្រះវិរិយៈឧស្សាហៈ ឲ្យសម្រេចប្រយោជន៍ដល់សត្វលោកជាច្រើន ។

ធម្មកាមតានេះ ធ្វើបុគ្គលជាន់ទាបឲ្យក្លាយទៅជាបុគ្គលជាន់ខ្ពស់ ធ្វើបុថុជ្ជនឲ្យក្លាយទៅជាអរិយបុគ្គល ព្រោះអាចធ្វើដំណើរឈានឡើងទៅកាន់សេចក្តីចំរើនខាងមុខ សមដូចសុភាសិតថា ធម្មកាមោ ភវំ ហោតិ អ្នកប្រាថ្នារបស់ប្រពៃ នាំឲ្យបានសេចក្តីចំរើន ។ អាស្រ័យសេចក្តីព្យាយាមប្រឹងប្រែងមិនបន្ធូរបន្ថយនេះហើយ ដែលអាចអប់រំសម្មា-បដិបត្តិឲ្យប្រសើរថ្កុំថ្កើងឡើងបាន ថែមទាំងឲ្យបានសេចក្តីរីករាយសប្បាយចិត្ត ដោយនឹករំពឹងថា អាត្មាអញបានធ្វើសមគួរហើយ ខ្លួនឯងតិះដៀលខ្លួនឯងមិនបាន ទាំងវិញ្ញូជនក៏រមែងសរសើរ ព្រមទាំងមិនបានក្តៅក្រហាយចិត្តខាងក្រោយទៀត ។ សម្តេចព្រះលោកនាថទ្រង់ត្រាស់ថា អ្នកដែលតាំងនៅក្នុងធម៌ជាទីពឹងឈ្មោះថាបានធ្វើកោះសម្រាប់ទីពឹងដល់ខ្លួន សមដូចធម្មភាសិតដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា

ធម្មទីបា ភិក្ខវេ វិហរថ ធម្មប្បដិសរណា អនញ្ញសា សេចក្តីថា ម្នាលភិក្ខុទាំងឡាយ លោកទាំងឡាយចូរមានធម៌ជាកោះទីពឹងពំនាក់ កុំមានវត្ថុដទៃជាសរណៈឡើយ ។ ព្រះអង្គទ្រង់សំដែងធម្មកថានេះ មិនមែនចំពោះតែពួកភិក្ខុប៉ុណ្ណោះទេ សូម្បីគ្រហស្ថក៏គួរកាន់បញ្ចូលបានដែរ ថ្វីបើព្រះអង្គទ្រង់ត្រាស់ចំពោះតែពួកភិក្ខុប៉ុណ្ណោះ ។ ពុទ្ធបរិស័ទដែលមានសេចក្តីប្រាថ្នាកុសលធម៌ ឈ្មោះថាបានធ្វើទីពឹងដល់ខ្លួនស្រេចហើយ ទាំងប្រាកដថាជាអ្នកបូជាព្រះសាស្តាដោយធម្មានុធម្មប្បដិបត្តិផង ។

ចប់ធម្មនិប្បាយ ក្នុងធម្មកាមតាតែប៉ុណ្ណោះ ។